ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## ការប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងទិសដៅការងារសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

នាព្រឹកថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង៨: ៣០ នាទី នៅសាលសិក្ខាសាលាបណ្ណាល័យ បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងទិសដៅការងារសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានតួនាទីចាប់ពីអនុប្រធាននាយកដ្ឋានឡើងចំនួន១០២នាក់។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានសម្តែងនូវគារវកិច្ចចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងអង្គប្រជុំ និងបានផ្សព្វផ្សាយខ្សែវីដេអូស្តីពីលទ្ធផលការងារសម្រេចបានក្នុងខែតុលា និងទិសដៅការងារសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២០ ជូនអង្គប្រជុំជ្រាបដូចខាងក្រោម៖

### I.លទ្ធផលការងារសម្រេចបាន
### ១-មុខងារនីតិកម្ម

-បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី៤ ដើម្បីស្តាប់របាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៩ច្បាប់៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

២-សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ ៖

៣.១.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃម៉ាឡេស៊ី ស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៣.២.កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី បត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត

៨-លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើវិសោធកម្មពិធីសារម៉ុងរ៉េអាល់ស្តីពី សារធាតុបំផ្លាញស្រទាប់អូហ្សូន

៩-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។

**២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ**

-គណៈកម្មការទី២ បានអញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តថវិកា និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តព្រះវិហារ

-គណៈកម្មការទី៦ បានចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវិធានការនានាក្នុងការដោះស្រាយវិវាទក្នុង និងក្រៅប្រព័ន្ធតុលាការ នៅខេត្តព្រះសីហនុ និងខេត្តកោះកុង

-គណៈកម្មការទី៧ បានអញ្ជើញជួបសវនាការជាមួយរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដើម្បីឈ្វេងយល់ពីការវិវត្តរីកចម្រើនថ្មី បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យទៅមុខរបស់ក្រសួង

-គណៈកម្មការទី៩ និងក្រុមភូមិភាគទី៧ បានអញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីការរីកចម្រើន និងការអភិវឌ្ឍថ្មីៗ នៅខេត្តព្រះសីហនុ

-ក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ ស្ថានភាពសេដ្ឋកិច្ច និងសុខភាពសាធារណៈ នៅខេត្តបន្ទាយមានជ័យ។

**៣-មុខងារតំណាង**

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតី និងចូលរួមក្នុងពិធីផ្សេងៗរួមមាន៖

+ពិធីដង្ហែព្រះរាជដំណើរព្រះមហាក្សត្រ និងសម្តេចម៉ែ យាងទៅទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន

+ព្រះរាជពិធីសម្ពោធមណ្ឌលសុខភាពសម្តេចព្រះមហាសង្ឃរាជ **បួរ គ្រី** នៅខេត្តកណ្តាល

+ពិធីសូត្រមន្តអង្គកឋិនទានសាមគ្គី នៅវត្តទួលសុវណ្ណារាម រាជធានីភ្នំពេញ

+ពិធីគោរពវិញ្ញាណក្ខន្ធសពលោកជំទាវឧកញ៉ា **កែវ ម៉ាលី** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា

+ចុះពិនិត្យស្ថានភាពជំនន់ទឹកភ្លៀង និងសាកសួរសុខទុក្ខប្រជាពលរដ្ឋ នៅខណ្ឌដង្កោ រាជធានីភ្នំពេញ

-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុម កា** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងចូលរួមក្នុងពិធីផ្សេងៗរួមមាន៖

+ពិធីបូជាសពឯកឧត្តម **តឹម ហេង** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធាននាយកដ្ឋានរដ្ឋបាលនៃខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា នៅវត្តពោធិសត្ថារាម រាជធានីភ្នំពេញ

+ចុះពិនិត្យស្ថានភាពជំនន់ទឹកភ្លៀង សាកសួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋ នៅខណ្ឌដង្កោ រាជធានីភ្នំពេញ

-ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងចូលរួមក្នុងពិធីផ្សេងៗរួមមាន៖

+ព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ

+ទស្សនកិច្ចឈ្វេងយល់អំពីហេដ្ឋារចនាសម្ព័ន្ធ ការងារពាក់ព័ន្ធវិស័យកសិកម្ម ការសិក្សាស្រាវជ្រាវ និងការពិសោធន៍បច្ចេកទេសបណ្តុះកូនចេកអំបូង និងក្រូចពោធិ៍សាត់ នៅសាកលវិទ្យាល័យបាត់ដំបង

+ចុះពិនិត្យស្ថានភាពជំនន់ទឹកភ្លៀង សាកសួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តបាត់ដំបង

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីបញ្ចុះសពលោកជំទាវឧកញ៉ា **កែវ ម៉ាលី** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា ចុះសួរសុខទុក្ខ និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀង និងពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ តាកែវ កំពត កែប ពោធិ៍សាត់ កំពង់ធំ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងខេត្តកោះកុង

-ឯកឧត្តមអគ្គលេខាធិការ បានអញ្ជើញជួបសំណេះសំណាល និងនាំយកអំណោយមនុស្សធម៌ទៅប្រគល់ជូនអាជ្ញាធរមូលដ្ឋាន នៅសង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក សង្កាត់បាក់ខែង សង្កាត់កោះដាច់ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងឯកអគ្គរដ្ឋទូតសិង្ហបុរី ចូលជួបជម្រាបលា

-ឯកឧត្តមប្រធានគណៈកម្មការទី២ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភានិយាយភាសាបារាំង(APF) តាមប្រព័ន្ធវីដេអូ

-លោកជំទាវប្រធានគណៈកម្មការទី៩ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំវិសាមញ្ញរបស់បណ្តាញស្ត្រីនៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធវីដេអូ

-ឯកឧត្តមអគ្គលេខាធិការ បានអនុញ្ញាតឱ្យបេក្ខជនជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលជប៉ុនក្នុងក្របខណ្ឌកម្មវិធីអ្នកដឹកនាំវ័យក្មេង Young Leader's Program ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ណែនាំ។

**៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ និងជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀង

-បន្តយកចិត្តទុកដាក់លើការងារអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីជានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-ការបង្កើយគម្រោងជួសជុល និងកែលម្អអគារមួយចំនួន ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

-បន្តអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតវីដេអូ និងការបោះពុម្ព

-បានចុះជំរឿនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តយកចិត្តទុកដាក់មជ្ឈដ្ឋានដែលនៅខ្សោយ និងសមត្ថភាពផលិតសេវានៅទាប

-ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការៈ ចំណេះដឹង ជំនាញ ភាសា គ្រប់គ្រង ដឹកនាំ/បច្ចេកវិទ្យាព័ត៌មាន

-សិក្សាការរៀបចំ(PCA) ដំណាក់កាលបន្ទាប់ពី(PIC)ការរៀបចំ Legal Database របស់ព្រឹទ្ធសភា

-សិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានាឱ្យបានសមស្របនឹងដំណាក់កាលថ្មី

-ការបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល ដើម្បីទ្រទ្រង់ដំណើរការថវិការហូតដល់ចុងឆ្នាំ២០២០

-បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី គម្រោងបែងចែកកញ្ចប់ថវិកាប្រចាំឆ្នាំ២០២១ របស់ព្រឹទ្ធសភា ជូនរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-បានរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ១តុលា

-បានរៀបចំក្រុមគ្រូពេទ្យប្រចាំការពេលប្រជុំព្រឹទ្ធសភា។

**៦-ការបណ្តុះបណ្តាលធនធានមនុស្ស**

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៩វគ្គ មានសិក្ខាកាមចំនួន១៧២នាក់

-បានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សារបស់សមាជិក សមាជិកា មកពីសមាគមសាលាត្រាជូ សិក្ខាកាមចំនួន២៥នាក់។

**II. ទិសដៅការងារសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២០**

***១-សេវាទ្រទ្រង់មុខងារនីតិកម្ម៖***

*-ត្រៀមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖*

*១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុវត្តយល់ព្រមលើពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម*

*២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការហាមឃាត់អាវុធនុយក្លេអ៊ែរ*

*៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីមួយ វិសោធនកម្មកិច្ចព្រមព្រៀងស្តីពី ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន*

*៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារ ដើម្បីអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពី សេវាកម្ម*

*៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋឥណ្ឌា*

*៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការវិនិយោគរវាងបណ្តារដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន*

*៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុវត្តយល់ព្រមលើ៖*

*៧.១-ពិធីសារទី៣ស្តីពី សិទ្ធិសហការលើជើងហោះហើរក្នុងស្រុកក្នុងវង្វង់ទឹកដីនៃប្រទេសជាសមាជិកអាស៊ានណាមួយ*

៧.២-ពិធីសារទី២ស្តីពី សិទ្ធិហោះហើរកូធ័រមីណាល (Co-Terminal Rights) រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន

៨-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ និងទី១០នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

៩-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

១០-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

១១-សេចក្តីព្រាងច្បាប់ស្តីពី កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (២០២១-២០២៣)

១២-សេចក្តីព្រាងច្បាប់ស្តីពី ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៩-២០២៣)

១៣-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥២ មាត្រា៥៥ មាត្រា៥៩ នៃច្បាប់ស្តីពីសហជីព

១៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ

១៥-សេចក្តីព្រាងច្បាប់ស្តីពី មូលបត្ររដ្ឋ

១៦-សេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

១៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពី ការទទួលស្គាល់ទៅវិញទៅមកលើការផ្តល់អាជ្ញាបណ្ណក្រុមអាកាសយានិក។

**២-សេវាទ្រទ្រង់មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ៖**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញជួបសវនាការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣-សេវាទ្រទ្រង់មុខងារតំណាង៖**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ចុះបំពេញការងារនៅមូលដ្ឋាន និងចូលរួមក្នុងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ៖

-ត្រៀមរៀបចំពិធីជំនួបផ្លូវការរវាងថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភាជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានា

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន។

## ៥-ការអភិវឌ្ឍស្ថាប័ន៖

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានទំនាក់ទំនងកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍របស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត ដៃគូបណ្តុះបណ្តាលនានា។ល។)

-ត្រៀមរៀបចំរបាយការណ៍ចំណូល ចំណាយថវិកាព្រឹទ្ធសភាប្រចាំឆ្នាំ២០២០ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ត្រៀមរៀបចំបែងចែកកញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ ជូនរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-រៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធីលើមូលដ្ឋានរចនាសម្ព័ន្ធថ្មីរបស់អគ្គនាយកដ្ឋានទាំង៥

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យសំខាន់ៗ៖ បុណ្យឯករាជ្យជាតិ និងពិធីបុណ្យជាតិផ្សេងៗទៀត

-រៀបចំធនធានមនុស្សតាមយន្តការ និងការធ្វើ Job Description និងការចងសៀវភៅរូបថត និងប្រវត្តិរូប

-បោះពុម្ពជំណាច់ឆ្នាំ ៖ ទិនានុលេខន៍ ប្រតិទិន និងបោះពុម្ពឯកសារសំខាន់ៗបម្រើការដឹកនាំ និងគ្រប់គ្រង

-អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ត្រូវបង្កើន និងពង្រឹងយន្តការការងារតាមប្រព័ន្ធ Online ដើម្បីធានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាពជូនស្ថាប័នឱ្យបានល្អប្រសើរ

-បង្កើនការគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹកភ្លើង ការគ្រប់គ្រងការប្រើប្រាស់INTERNET

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងព្រឹទ្ធសភា

-រៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីEបណ្ណាល័យ និង Eបណ្ណសារ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាពគោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការប្រើប្រាស់ និងបំពាក់សម្ភារប្រជុំតាមប្រព័ន្ធវីដេអូ

-បន្តប្រជុំគណៈកម្មការគោលការណ៍ គោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងគ្រប់វិស័យនៃការងាររបស់ស្ថាប័ន។

**<u>មតិណែនាំរបស់ឯកឧត្តមអគ្គលេខាធិការ</u>**

បន្ទាប់ពីបានស្តាប់ការផ្សព្វផ្សាយលទ្ធផលការងារប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២០ **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបជូនអង្គប្រជុំបន្ថែមអំពីទិសដៅការងារសំខាន់ៗ សម្រាប់ការងារចុងឆ្នាំមួយចំនួនទៀតរួមមាន៖ ការរៀបចំផែនការការងារ ផែនការថវិកា ផែនការអភិវឌ្ឍន៍ធនធានមនុស្ស ផែនការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងការបូកសរុបលទ្ធផលការងារចុងឆ្នាំ។ បន្ថែមពីនេះទៀត **ឯកឧត្តមអគ្គលេខាធិការ** បានជំរុញឱ្យអគ្គនាយក-ដ្ឋានដែលមិនទាន់បានចងក្រងជាសៀវភៅ ត្រូវខិតខំបញ្ចប់ការងារចងក្រងឯកសារប្រវត្តិរូប និងពិពណ៌នាការងារឱ្យបានរួចរាល់នៅបំណាច់ឆ្នាំ។ ពិសេស ការបញ្ជូនបញ្ជីឈ្មោះមន្ត្រីខ្សោយមកអគ្គលេខាធិការដ្ឋាន ដើម្បីធ្វើការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបន្ថែមទៀត។ ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបជូនគ្រប់អគ្គនាយកដ្ឋាន និងនាយកដ្ឋានឱ្យផ្សព្វផ្សាយដល់មន្ត្រីដែលបានបំពេញការងារអស់រយៈពេល៣០ឆ្នាំ អាចស្នើ

សុំចូលនិវត្តបានដោយទទួលបានអត្ថប្រយោជន៍ពេញលេញ ពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ចំពោះការងារអភិវឌ្ឍន៍ស្ថាប័ន បានក្លាយជាការពិតហើយ ដោយភាគីចិនសន្យាជួយរៀបចំបណ្ណាល័យព្រឹទ្ធសភា ឱ្យក្លាយទៅជាបណ្ណាល័យអេឡិចត្រូនិច។ ចំណែកការងារសហប្រតិបត្តិ-ការអន្តរជាតិ វិទ្យាស្ថានសភាកម្ពុជា (PIC) កំពុងចាប់ដំណើរការនីតិវិធី និងបែបបទ ដើម្បីប្រែក្លាយទៅជាវិទ្យាស្ថានសភាអាស៊ី (PCA) វិញនាពេលខាងមុខ ដោយវិទ្យាស្ថានសភាអាស៊ី (PCA) **ឯកឧត្តមអគ្គលេខាធិការ** ជានាយកប្រតិបត្តិបន្តទៀត។

មុននឹងបញ្ចប់**ឯកឧត្តមអគ្គលេខាធិការ** ស្នើឱ្យគ្រប់អគ្គនាយកដ្ឋាន និងនាយកដ្ឋានទាំងអស់ត្រូវយកចិត្តទុកដាក់ និងចូលរួមថែរក្សាបរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ ជាពិសេសការវេចខ្ចប់សំរាម ការចោលសំរាម និងការចតយានយន្តឱ្យបានត្រឹមត្រូវ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០.៤៥ នាទីព្រឹក ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល ប្រកបដោយស្មារតីទទួលខុសត្រូវ ។

ថ្ងៃសុក្រ ៦រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ប្រធាននាយកដ្ឋាន**

**ឡាំង ថន**

**បានឃើញ និងឯកភាព**
**អគ្គលេខាធិការ**

**អ៊ុំ_សារឹទ្ធ**

**បានឃើញ និងឯកភាព**
**អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**

**ឈឹម ព្រះខ័ន**